# ការដាក់វិន័យដល់កូនៗតាមរបៀបរបស់ព្រះអម្ចាស់

សូមអញ្ជើញសមាជិកក្រុមឲ្យស្រមៃថា ពួកគេគឺជាឪពុកឬ ម្ដាយមួយរូប ។ សូមឲ្យពួកគេជ្រើសរើសយកស្ថានភាពមួយពីស្ថានភាពខាងក្រោមនេះមកពិភាក្សាជាមួយគ្នា ៖

១. នៅពេលអ្នកមកដល់ផ្ទះវិញ ពីការទិញគ្រឿងទេសជាមួយនឹងកូនៗរបស់អ្នក នោះអ្នកឃើញកូនស្រីអាយុប្រាំមួយឆ្នាំរបស់អ្នកកំពុងញ៉ាំស្ករគ្រាប់មួយបន្ទះ ដែលនាងបានលួចមកពីហាង ។

២. កូនប្រុសអាយុ ១៤ ឆ្នាំ របស់អ្នកតែងតែធ្វើបាបប្អូនប្រុសអាយុ ៩ ឆ្នាំរបស់គាត់ជានិច្ច ។ ជាធម្មតា រឿងនេះកើតឡើងនៅពេលអ្នកមិននៅជាមួយពួកគេ ។ កូនប្រុសដែលត្រូវបងធ្វើបាបនោះ ដើរមករកអ្នកទាំងទឹកភ្នែក ហើយប្រាប់អ្នកថា បងប្រុសរបស់គាត់បាននិយាយពាក្យមិនល្អដាក់គាត់ទៀតហើយ ។

៣. អ្នកកំពុងរង់ចាំកូនស្រីអាយុ ១៧ ឆ្នាំរបស់អ្នកត្រឡប់មកពីផ្ទះមិត្តភក្តិនាងវិញ ។ នៅពេលនាងមកដល់ផ្ទះ នោះវាហួសម៉ោងចូលផ្ទះរបស់នាងបាត់ទៅហើយ ។

សូមឲ្យក្រុមរបស់អ្នកពិភាក្សាពីសំណួរខាងក្រោមនេះ នៅពេលពួកគេយល់ពីស្ថានភាព ដែលពួកគេបានជ្រើសរើសនោះ ៖

- តើអ្វីដែលអ្នកបានរៀនមកពី ផ្នែកទី ២ នៃឯកសាររៀបចំ អាចណែនាំអ្នកក្នុងការដាក់វិន័យដល់កូនរបស់អ្នកដោយរបៀបណា ? ( ប្រសិនបើចាំបាច់ សូមអញ្ជើញសមាជិកក្រុមរបស់អ្នកឲ្យពិនិត្យផ្នែកទី ២ ឡើងវិញមួយភ្លែត ) ។
- តើការសន្ទនារបស់អ្នកជាមួយនឹងកូនរបស់អ្នក នឹងមានសភាពយ៉ាងណាដែរ ? តើអ្នកអាចដាក់ពិន័យអ្វីខ្លះ ចំពោះសកម្មភាពរបស់កូនអ្នក ?
- តើការដាក់វិន័យត្រឹមត្រូវដល់កូន គឺជាទង្វើនៃសេចក្ដីស្រឡាញ់តាមរបៀបណា ? ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១ ) ។

— — — — — — — — — — — — — — — — — — — — —

សូមអញ្ជើញសមាជិកក្រុមឲ្យស្រមៃថា ពួកគេគឺជាឪពុកឬ ម្ដាយមួយរូប ។ សូមឲ្យពួកគេជ្រើសរើសយកស្ថានភាពមួយពីស្ថានភាពខាងក្រោមនេះមកពិភាក្សាជាមួយគ្នា ៖

១. នៅពេលអ្នកមកដល់ផ្ទះវិញ ពីការទិញគ្រឿងទេសជាមួយនឹងកូនៗរបស់អ្នក នោះអ្នកឃើញកូនស្រីអាយុប្រាំមួយឆ្នាំរបស់អ្នកកំពុងញ៉ាំស្ករគ្រាប់មួយបន្ទះ ដែលនាងបានលួចមកពីហាង ។

២. កូនប្រុសអាយុ ១៤ ឆ្នាំ របស់អ្នកតែងតែធ្វើបាបប្អូនប្រុសអាយុ ៩ ឆ្នាំរបស់គាត់ជានិច្ច ។ ជាធម្មតា រឿងនេះកើតឡើងនៅពេលអ្នកមិននៅជាមួយពួកគេ ។ កូនប្រុសដែលត្រូវបងធ្វើបាបនោះ ដើរមករកអ្នកទាំងទឹកភ្នែក ហើយប្រាប់អ្នកថា បងប្រុសរបស់គាត់បាននិយាយពាក្យមិនល្អដាក់គាត់ទៀតហើយ ។

៣. អ្នកកំពុងរង់ចាំកូនស្រីអាយុ ១៧ ឆ្នាំរបស់អ្នកត្រឡប់មកពីផ្ទះមិត្តភក្តិនាងវិញ ។ នៅពេលនាងមកដល់ផ្ទះ នោះវាហួសម៉ោងចូលផ្ទះរបស់នាងបាត់ទៅហើយ ។

សូមឲ្យក្រុមរបស់អ្នកពិភាក្សាពីសំណួរខាងក្រោមនេះ នៅពេលពួកគេយល់ពីស្ថានភាព ដែលពួកគេបានជ្រើសរើសនោះ ៖

- តើអ្វីដែលអ្នកបានរៀនមកពី ផ្នែកទី ២ នៃឯកសាររៀបចំ អាចណែនាំអ្នកក្នុងការដាក់វិន័យដល់កូនរបស់អ្នកដោយរបៀបណា ? ( ប្រសិនបើចាំបាច់ សូមអញ្ជើញសមាជិកក្រុមរបស់អ្នកឲ្យពិនិត្យផ្នែកទី ២ ឡើងវិញមួយភ្លែត ) ។
- តើការសន្ទនារបស់អ្នកជាមួយនឹងកូនរបស់អ្នក នឹងមានសភាពយ៉ាងណាដែរ ? តើអ្នកអាចដាក់ពិន័យអ្វីខ្លះ ចំពោះសកម្មភាពរបស់កូនអ្នក ?
- តើការដាក់វិន័យត្រឹមត្រូវដល់កូន គឺជាទង្វើនៃសេចក្ដីស្រឡាញ់តាមរបៀបណា ? ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១ ) ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved.